**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# លទ្ធិប្រជាធិបតេយ្យនៅសម័យឌីជីថល និងការគំរាមកំហែងដល់ សេរីភាពបុគ្គលភាព និងឯកជន

ស្រាវជ្រាវដោយៈ លោកស្រី **ផាវ ច័ន្ទម៉ាទីន**

ដោយមានការចូលរួមពីៈ លោក **ហ៊ីស័រ រាជស៊ី វ៉ាណូ**

ខែតុលា ឆ្នាំ ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយ ដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

# មាតិកា


លទ្ធិប្រជាធិបតេយ្យនៅសម័យឌីជីថល ........................................ 1

១. ឥទ្ធិពលនៃសម័យឌីជីថល (Digital Age) នៅក្នុងលទ្ធិប្រជាធិបតេយ្យ ........................................ 2

២. ផលប៉ះពាល់ទៅលើសិទ្ធិឯកជន និងសេរីភាពបុគ្គល ........................................ 2

៣. ច្បាប់ និងគោលនយោបាយក្នុងការការពារសិទ្ធិឯកជន និងសេរីភាពបុគ្គលនៅសម័យឌីជីថល ខណៈពេលដែលលើកតម្កើងលទ្ធិប្រជាធិបតេយ្យ ........................................ 3

៤. ការប្រៀបធៀបសិទ្ធិឯកជនរបស់អង្គការសហប្រជាជាតិ ជាមួយនឹងគំនិតផ្តួចផ្តើមទាំងឡាយ ដែលកម្ពុជាអាចអនុវត្តដើម្បីពង្រឹងសិទ្ធិឯកជន ........................................ 3

សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ ........................................ 5

គន្ថនិទ្ទេស ........................................ Error! Bookmark not defined.

# លទ្ធិប្រជាធិបតេយ្យនៅសម័យឌីជីថល

នៅក្នុង «សម័យឌីជីថល»[1] បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា(ICT) ដូចជាប្រព័ន្ធអ៊ីនធឺណែត និងកម្មវិធីឌីជីថល(Digital Platforms)ផ្សេងៗ (ឧទាហរណ៍បណ្តាញទំនាក់ទំនងសង្គមដូចជា *Facebook, Twitter, Instagram, LinkIn, WordPress, and Tumblr*) បានធ្វើឲ្យមានការប្រែប្រួលយ៉ាងខ្លាំងទៅលើស្ថាប័ននយោបាយ សកម្មភាព និងទំនាក់ទំនងទូទៅ។[2] សម័យឌីជីថល(Digital Age)នេះផ្តល់ឱកាសឲ្យប្រជាជនធ្វើការប្រាស្រ័យទាក់ទងទទួលព័ត៌មានថ្មីៗ និងបញ្ចេញគំនិតរបស់ពួកគេនៅក្នុងកម្មវិធីឌីជីថលនានា។ នៅក្នុងបរិបទនៃលទ្ធិប្រជាធិបតេយ្យ កម្មវិធីឌីជីថលទាំងអស់នេះអាចជួយបង្កើនការចូលរួមរបស់ប្រជាជននៅក្នុងការជជែកដេញដោលជាសាធារណៈ និងចូលរួមនៅក្នុងការសម្រេច ព្រមទាំងបង្កើនសមត្ថភាពរបស់ពួកគាត់ក្នុងទទួលបាននូវព័ត៌មានដែលអាចជួយឲ្យប្រជាជនកាន់តែយល់ដឹងបន្ថែមពីសកម្មភាពរបស់រាជរដ្ឋាភិបាល។ លើសពីនេះទៀតកម្មវិធីឌីជីថល(Digital Platforms)អាចផ្តល់មធ្យោបាយដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនមួយចំនួនក្នុងការប្រមូលនូវព័ត៌មានពីសកម្មភាពអនឡាញ (online) របស់ប្រជាពលរដ្ឋ។ ស្ថានភាពនេះបង្ហាញពីផលប៉ះពាល់ទៅលើសិទ្ធិសេរីភាពឯកជន និងបុគ្គលដែលអាចកើតមានឡើងសូម្បីតែក្នុងប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យផងដែរ។[3]

ឯកសារសង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅនៃលទ្ធិប្រជាធិបតេយ្យនៅសម័យឌីជីថល ជាពិសេសផ្តោតទៅលើផលប៉ះពាល់ទៅលើសិទ្ធិឯកជន និងសេរីភាពរបស់បុគ្គលម្នាក់ៗ ដែលនឹងយកទៅពិភាក្សា នៅក្នុងអង្គប្រជុំសហភាពអន្តរសភា លើកទី១៣៣ ដែលនឹងប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ពីថ្ងៃទី១៧ ដល់ ២១ ខែតុលា ឆ្នាំ២០១៥។ លើសពីនេះទៅទៀត អត្ថបទនេះនឹងផ្តល់នូវការប្រៀបធៀបសិទ្ធិឯកជនដែលបានដាក់ចេញឡើងដោយអង្គការសហប្រជាជាតិ ជាមួយនឹងគំនិតផ្តួចផ្តើមដើម្បីធ្វើឲ្យសិទ្ធិឯកជននៅប្រទេសកម្ពុជាមានភាពល្អប្រសើរឡើង។

---

[1] សម័យឌីជីថល សំដៅលើ សម័យពត៌មានវិទ្យាដែលគេស្គាល់ថា សម័យកុំព្យូទ័រ សម័យឌីជីថល សម័យប្រព័ន្ធផ្សព្វផ្សាយថ្មីៗ។ នេះគឺជារយៈពេលនៅក្នុងប្រវត្តិសាស្ត្រមនុស្សដែលត្រូវបានកំណត់ដោយការផ្លាស់ប្តូរដោយឧបករណ៍បច្ចេកវិទ្យា។

[2] Nash and Bright, "Digital Era Government and Politics", (Oxford University: 2015), p 1

[3] Inter-Parliamentary Union, *Democracy in the digital era and the threat to privacy and individual freedoms,* (132nd IPU Assembly: Hanoi (Viet Nam), 28 March-1 April 2015).

## ១. ឥទ្ធិពលនៃសម័យឌីជីថលនៅក្នុងលទ្ធិប្រជាធិបតេយ្យ

អ្នកជំនាញមានគំនិតខុសៗគ្នា ទៅលើផលប៉ះពាល់ និងសារៈសំខាន់នៃប្រព័ន្ធអ៊ិនធើណែត ព្រមទាំងបច្ចេកវិទ្យាដែលពាក់ព័ន្ធទៅនឹងគោលបំណងនយោបាយរបស់រាជរដ្ឋាភិបាល។[4] សម័យឌីជីថល ត្រូវបានចាត់ទុកថាជាអំឡុងពេលនៃការផ្លាស់ប្តូរនៃបរិបទនយោបាយ ដែលក្នុងនោះប្រជាពលរដ្ឋមានឱកាសទទួលបានមធ្យោបាយបន្ថែម ដើម្បីត្រួតពិនិត្យទៅលើសកម្មភាពរបស់សភា។[5] ម្យ៉ាងវិញទៀតសម័យនេះ ក៏អាចបង្កឲ្យមានហានិភ័យ និងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរផងដែរ ដោយសាររដ្ឋាភិបាលកាន់តែប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (Digital Technology) នៅក្នុងកិច្ចការរបស់ខ្លួន។[6] លើសពីនេះទៅទៀត លិទ្ធិប្រជាធិបតេយ្យក៏អាចជួបនូវគ្រោះថ្នាក់ដោយសារតែការកើនឡើងនៃហានិភ័យទៅលើការបំពានភាពជាឯកជនរបស់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប។ [7] សកម្មភាពទាំងនេះសបញ្ជាក់ពីសារៈសំខាន់សម្រាប់សភាដើម្បីបង្កើតច្បាប់ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ តាមដាន និងត្រួតពិនិត្យទៅលើការអនុវត្តច្បាប់ផងដែរ។[8]

## ២. ផលប៉ះពាល់ទៅលើសិទ្ធិឯកជន និងសេរីភាពបុគ្គល

សេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមគឺជាលក្ខខណ្ឌមូលដ្ឋាននៃលិទ្ធិប្រជាធិបតេយ្យ។[9] ការកើនឡើងនូវបច្ចេកវិទ្យាព័ត៌មាន ជាមួយនឹងសមត្ថភាពក្នុងការប្រមូល ការវិភាគ និងការចែកចាយ ទិន្នន័យបុគ្គលត្រូវបានចាត់ទុកជាបញ្ហាបន្ទាន់ក្នុងការបង្កើតច្បាប់សម្រាប់ដោះស្រាយបញ្ហា។ [10] ទន្ទឹមនឹងនេះប្រជាជននៅលើពិភពលោកបានបញ្ចេញនូវភាពភ័យខ្លាចអំពី ការរំលោភបំពានទៅលើសិទ្ធិឯកជន និងសេរីភាពបុគ្គល។ ក្រុមសិទ្ធិមនុស្ស ក៏បានបង្ហាញពីការព្រួយបារម្ភនៅក្នុងការនាំចេញនូវបច្ចេកវិទ្យាទៅកាន់ប្រទេសដែលកំពុងអភិវឌ្ឍន៍ដែលពុំមានយន្តការគ្រប់គ្រាន់ក្នុងការការពារសិទ្ធិ និងសេរីភាពបុគ្គល។ ទោះជាយ៉ាងណា ការវាយតំលៃ និងបទ-ប្បញ្ញត្តិទៅលើបច្ចេកវិទ្យាទាំងអស់នេះ នៅតែជាបញ្ហាប្រឈម។

---

4 Nash and Bright, ''Digital Era Government and Politics'', (Oxford University: 2015), p 1
5 Global Centre for ICT in parliament, "Chapter 1: Major Global Trends since 2010 and possible Developments beyond 2012, *World e-Parliament Report 2012*, (United Nation: 2012).
6 Nash and Bright, ''Digital Era Government and Politics'', (Oxford University: 2015), p 1
7 Inter-Parliamentary Union, *Democracy in the digital era and the threat to privacy and individual freedoms,* (132ndIPU Assembly: Hanoi (Viet Nam), 28 March-01 April 2015).
8 Ibid.
9 Ibid.
10 David Bansiar, *Privacy and Human Rights: A International survey of privacy laws and practice*, (Global Internet Liberty Campaign).

## ៣. ច្បាប់ និងគោលនយោបាយក្នុងការការពារសិទ្ធិឯកជន និងសេរីភាពបុគ្គល នៅសម័យឌីជីថល ខណៈពេលដែលលើកតម្កើងលទ្ធិប្រជាធិបតេយ្យ

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិឯកជនតាមការតម្រូវរបស់រដ្ឋធម្មនុញ្ញ មានដូចខាងក្រោម៖

- មាត្រា ៣១ (កថាខណ្ឌទី២)៖ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ទិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដ៏ទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។[11]
- មាត្រា ៣៥៖ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីស្ថាប័នរដ្ឋ។[12]
- មាត្រា ៤១៖ ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពនៃការជួបប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដ៏ទៃ ឬទំនៀមទម្លាប់ល្អរបស់សង្គម ឬសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិបានឡើយ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។[13]

លើសពីនេះទៀត ក្រុមការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រីក៏កំពុងតែរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេតផងដែរ។ [14]

## ៤. ការប្រៀបធៀបសិទ្ធិឯកជនរបស់អង្គការសហប្រជាជាតិ ជាមួយនឹងគំនិតផ្តួចផ្តើមនានាដែលកម្ពុជាអាចអនុវត្តដើម្បីពង្រឹងសិទ្ធិឯកជន

ចាប់ពីខែធ្នូ ឆ្នាំ២០១៣ ដល់ខែធ្នូ ឆ្នាំ២០១៤ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចស្តីពីសិទ្ធិឯកជននៅសម័យឌីជីថល (Right to Privacy in the Digital Age) ដើម្បីធានាថាបណ្តារដ្ឋជាសមាជិកទាំងអស់ត្រូវស្ថិតនៅក្នុងការអនុលោមតាមកាតព្វកិច្ចនៅក្រោមច្បាប់អន្តរជាតិ។[15] តារាងទី១ ខាង

[11] Chapter 3: the rights and obligations of Khmer citizens, *Constitution of the Kingdom of Cambodia*, (2008).
[12] Ibid.
[13] Ibid.
[14]
[15] Inter-Parliamentary Union, *Democracy in the digital era and the threat to privacy and individual freedoms,* (132nd IPU Assembly: Hanoi (Viet Nam), 28 March-01 April 2015).

ក្រោមនេះគឺជាការប្រៀបធៀបសេចក្តីសម្រេចទាំងឡាយរបស់អង្គការសហប្រជាជាតិជាមួយសេចក្តីផ្តួចផ្តើម ផ្នែកច្បាប់និងគោលនយោបាយទាំងឡាយ ដែលប្រទេសកម្ពុជាអាចទទួលយកមកអនុវត្ត។

*តារាងទី ១ ការប្រៀបធៀបសេចក្តីផ្តួចផ្តើមផ្នែកច្បាប់ និងគោលនយោបាយទាំងឡាយ របស់អង្គការសហប្រជា-ជាតិ និងរបស់កម្ពុជា*

| សិទ្ធិឯកជនភាពរបស់អង្គការសហប្រជាជាតិ | គំនិតផ្តួចផ្តើមរបស់ប្រទេសកម្ពុជាស្តីពីសិទ្ធិឯកជន |
|---|---|
| • ធានានូវសិទ្ធិឯកជន ថាគ្មាននរណាម្នាក់អាចជ្រៀតជ្រែកដោយខុសច្បាប់ទៅលើឯកជនភាពរបស់បុគ្គលម្នាក់ ឬក្រុមគ្រួសារឡើយ។[16]<br>• ទទួលស្គាល់ពីភាពប្រសើរឡើងលើព័ត៌មាន និងទំនាក់ទំនងបច្ចេកវិទ្យាដែលជួយពន្លឿនភាពរីកចម្រើនឲ្យបានឆាប់រហ័សក្នុងការអភិវឌ្ឍន៍។[17]<br>• គាំទ្រនិងទទួលស្គាល់ថា អ្នកនៅក្នុងបណ្តាញត្រូវតែទទួលបានការការពារ ដូចគ្នានឹងអ្នកនៅក្រៅបណ្តាញដែរ រួមទាំងសិទ្ធិឯកជនភាព។[18]<br>• ធ្វើការអំពាវនាវដល់បណ្តាប្រទេសទាំងឡាយឲ្យ៖[19]<br>➢ គោរព និងការពារសិទ្ធិឯកជន។<br>➢ ចាត់វិធានការ និងបង្កើតលក្ខខណ្ឌដើម្បីទប់ស្កាត់ការរំលោភបំពានលើសិទ្ធិឯកជនដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ។<br>➢ ត្រួតពិនិត្យឡើងវិញនូវនីតិវិធី ការអនុវត្តន៍ និងច្បាប់ដែលទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នា រារាំង និងការប្រមូល ទិន្នន័យរបស់បុគ្គលណាម្នាក់។ | ការផ្តួចផ្តើមទាំងឡាយពាក់ព័ន្ធសិទ្ធិឯកជនដែលទាក់ទងទៅនឹងបច្ចេកវិទ្យាឌីជីថលអាចរួមបញ្ចូលដូចជា៖<br>• ធានាសេរីភាពក្នុងការបញ្ចេញមតិដោយធានាថាអ៊ិនធើណេតមិនត្រូវបានជ្រៀតចូលដោយអ្នកប្រើប្រាស់ខុសច្បាប់ (ក្រុមហេកកឺ-hackers ក្រុមជ្រុលនិយម-extremists និងក្រុមអ្នកលួចចំលងខុសច្បាប់-piracy)។[20]<br>• បង្កើតក្របខ័ណ្ឌច្បាប់មួយដែលច្បាស់លាស់ និងធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ដើម្បីការពារ និងលើកកម្ពស់សិទ្ធសេរីភាពក្នុងការបញ្ចេញមតិដោយអនុលោមតាមស្តង់ដាសិទ្ធិមនុស្សអន្តរ-ជាតិ។[21]<br>• ធ្វើការអភិវឌ្ឍន៍គោលនយោបាយ និងជួយសម្រួលដល់ការប្រើប្រាស់អ៊ិនធើណេត របស់ប្រជាជនកម្ពុជា។[22]<br>• អនុវត្តគោលនយោបាយដែលអនុញ្ញាតឲ្យប្រជាជនកម្ពុជាសិក្សាស្វែងយល់ពីការប្រើប្រាស់ |

[16] United Nations, *the right to privacy in the digital age,* ( 18 December,2013).
[17] Ibid.
[18] Ibid.
[19] Ibid.
[20] Cambodian Center for Human Rights, *New Media and the Promotion of Human Rights in Cambodia,*(July, 2012)
[21] Ibid.
[22] Ibid.

| | |
|---|---|
| ➢ បង្កើតឬរក្សានូវប្រសិទ្ធភាពដែលមានលក្ខណៈឯករាជ្យក្នុងការត្រួតពិនិត្យ និងការតាមដានសកម្មភាពរបស់រដ្ឋដែលទាក់ទងទៅនឹងសិទ្ធិឯកជន។ | ប្រព័ន្ធអ៊ិនធើណេត។[23]<br>• គាំទ្រសិទ្ធិទទួលបានព័ត៌មាន និងផ្សព្វផ្សាយសាធារណៈនូវព័ត៌មានផ្លូវការតាមប្រព័ន្ធអ៊ិនធើណែត។[24] |

ទោះបីជាយ៉ាងណា ដើម្បីឲ្យគំនិតផ្តួចផ្តើមទាំងនេះឆ្ពោះទៅមុខបាន ហើយដើម្បីអនុវត្តនូវសភាអេឡិចត្រូនិច និងរដ្ឋាភិបាលអេឡិចត្រូនិចបាន ប្រទេសកម្ពុជាត្រូវតែរកដំណោះស្រាយចំពោះបញ្ហាចំបង២ គឺកង្វះខាតថវិកា និងធនធានមនុស្ស ។

## សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ

សម័យឌីជីថល (Digital Age) បានផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាចូលរួមក្នុងឆាកនយោបាយ និងបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប។ ប្រជាជនកម្ពុជាត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ មាត្រា ៣៥ និងមាត្រា ៤១ រួមទាំងសេចក្តីព្រាងច្បាប់ថ្មីស្តីអំពី ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធើណេត។ ក៏ប៉ុន្តែ កង្វះខាតថវិកា និងធនធានមនុស្សនៅតែជាបញ្ហាប្រឈមចំពោះព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តន៍សភាអេឡិចត្រូនិច (E-Parliament) និងរដ្ឋាភិបាលអេឡិចត្រូនិច (E-Government)។ដោយសារតែ តួនាទីរបស់សភាដែលជាសមាជិកនៅក្នុងសហភាពអន្តរសភាគឺធ្វើការសហការណ៍ និងផ្លាស់ប្តូរនូវបទពិសោធន៍ជាមួយសភាដទៃទៀតដែលជាសមាជិកធ្វើការពិចារណាទៅលើបញ្ហាប្រឈម និងធ្វើការបញ្ចេញមតិយោបល់ទាក់ទងទៅនឹងបញ្ហាប្រឈម ដែលត្រូវបានលើកឡើងនៅក្នុងអង្គប្រជុំសហភាពអន្តរសភា។ [25] គួរតែប្រើប្រាស់អង្គប្រជុំនោះឲ្យបានល្អប្រសើរជាងមុន ដើម្បីកំណត់នូវដំណោះស្រាយ ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ប្រទេសកម្ពុជា។ សេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមគឺជាលក្ខខណ្ឌមូលដ្ឋាននៃលិទ្ធិប្រជាធិបតេយ្យ ដោយនាពេលបច្ចុប្បនេះ ប្រជាពលរដ្ឋភាគច្រើនធ្វើការបញ្ចេញមតិរបស់ខ្លួន ឬទទួលបានព័ត៌មានថ្មីៗតាមរយៈ កម្មវិធីឌីជីថលផ្សេងៗដូចជា បណ្តាញទំនាក់ទំនងសង្គម *Facebook* និង*Twitter* ជាដើម។ ដើម្បីគ្រប់គ្រងទៅលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនៅក្នុងលទ្ធិប្រជាធិបតេយ្យក៏ដូចជាដើម្បីពង្រឹងទៅលើកិច្ចការពារភាពឯកជន និងសេរីភាពបុគ្គល សមាជិក និងសមាជិកាសភាអាចពិចារណាទៅលើជម្រើសនៃគោលនយោបាយ ដែលមានដូចជា៖

[23] Ibid.
[24] Ibid.
[25] Inter-Parliamentary Union, http: http://www.ipu.org/english/home.htm

- ធ្វើការសហការណ៍ជាមួយនឹងអង្គការសហប្រជាជាតិ និងបណ្តាប្រទេសនានាដែលជាសមាជិកនៅក្នុងសហភាពអន្តរសភាដើម្បីបង្កើតនូវច្បាប់អន្តរជាតិមួយក្នុងគោលបំណងគាំពារទៅលើសិទ្ធិឯកជន និងសេរីភាពបុគ្គលនៅក្នុង លទ្ធិប្រជាធិបតេយ្យ។
- ពង្រឹងទៅលើការអប់រំក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប និងអត្ថប្រយោជន៍ក្នុងការប្រើប្រាស់នូវកម្មវិធីឌីជិថលផ្សេងៗ នៅក្នុងបរិបទនយោបាយ ការវិនិយោគអាជីវកម្ម និងការទទួលបានព័ត៌មានថ្មីៗជុំវិញពិភពលោក។
- ពង្រឹង និងធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធដែលមានស្រាប់ ដោយកំណត់ឲ្យបានច្បាស់អំពីការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដែលអាចធ្វើឲ្យមានការរំលោភបំពានទៅលើ ភាពឯកជនរបស់បុគ្គលណាម្នាក់តាមរយៈការគម្រាមកំហែងជាដើម។[26]
- ពន្លឿននូវដំណើរការក្នុងការអនុម័តច្បាប់ស្តីពី ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធើណែតដើម្បីបង្ការនូវការគម្រាមកំហែងដល់ភាពឯកជន និងសេរីភាពបុគ្គល។[27]
- សហការណ៍ជាមួយបណ្តាប្រទេសនីមួយៗដែលជាសមាជិកនៅក្នុងសហភាពអន្តរសភាដើម្បីបង្កើតនូវ "មូលដ្ឋានទិន្នន័យ (Database)" សំរាប់ផ្ទុកនូវរាល់ពាក្យបណ្តឹង ពីបណ្តាប្រទេសទាំងឡាយដែលជាសមាជិក អំពីការរំលោភបំពាន ការគម្រាមកំហែងលើភាពឯកជន និងសេរីភាពបុគ្គលដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប។
- រៀបចំសេចក្តីព្រាងច្បាប់អន្តរជាតិមួយស្តីពី "ការគ្រប់គ្រងប្រព័ន្ធអ៊ិនធើណែត" ដើម្បីការពារនូវការជ្រៀតចូលពីភេរវករ ៕

[26] Constitution of the Kingdom of Cambodia *"Article 31, 35 and 41"*, http: http://www.crrt-cambodia.org/wp-content/uploads/2011/01/Constitution-of-the-kingdom-of-Cambodia-EN.pdf
[27]Council of Ministers, ''Draft Law on Cyber Crime'', accessed on October 2, 2015, URL: https://www.article19.org/data/files/medialibrary/37516/Draft-Law-On-CyberCrime_Englishv1.pdf

# ឯកសារយោង

Cambodian Center for Human Rights, *Cyber Laws: Tools for Protecting or Restricting Freedom of Expression.* CCHR Briefing Note, February 2014. https://www.ifex.org/cambodia/2014/03/03/cambodia_cyber_crimes_legislation_cchr.pdf.

Cambodian Center for Human Rights. *New Media and the Promotion of Human Rights in Cambodia.* July, 2012 http://www.cchrcambodia.org/admin/media/report/report/english/2012_07_24_New_Media_and_the_Promotion_of_Human_Rights_in_Cambodia_ENG.pdf

*Constitution of the Kingdom of Cambodia.* 2008. http://www.crrt-cambodia.org/wp-content/uploads/2011/01/Constitution-of-the-kingdom-of-Cambodia-EN.pdf.

Cybercrime Law Formulation Working Group of Council of Ministers, *Cybercrime Law*. https://www.article19.org/data/files/medialibrary/37516/Draft-Law-On-CyberCrime_Englishv1.pdf.

David Bansiar. *Privacy and Human Rights: A International survey of privacy laws and practice*. Global Internet Liberty Campaign. http://gilc.org/privacy/survey/intro.html.

Global Centre for ICT in parliament. "Chapter 1: Major Global Trends since 2010 and possible Developments beyond 2012."*World e-Parliament Report 2012*. United Nation: 2012. http://www.ictparliament.org/sites/default/files/wepr2012_-_chapter1.pdf.

Inter-Parliamentary Union. *Democracy in the digital era and the threat to privacy and individual freedoms*. 132nd IPU Assembly: Hanoi (Viet Nam). 28 March-1 April 2015. http://www.ipu.org/conf-e/132/3cmt-7-inf1.pdf.

Jonathan Cox. *Crowdsourcing Cambodia's online Bill of Rights*. Khmer Time: Monday, 03 August, 2015. http://www.khmertimeskh.com/news/14004/crowdsourcing-cambodia---s-online-bill-of-rights/.

Nash and Bright. ''Digital Era Government and Politics''. Oxford University: 2015.

United Nations. *the right to privacy in the digital age.* 18 December,2013. http://www.un.org/ga/search/view_doc.asp?symbol=A/RES/68/167